ACCESS 2
Sustainable quality services for all

Australian Aid

# កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2) ខេត្តកំពង់ស្ពឺ

## កម្មវិធី ACCESS 2 ជាការបន្តនៃការវិនិយោគទ្វេភាគីនៃប្រទេសអូស្ត្រាលី លើការងារសមភាពយេនឌ័រ ពិការភាព ការស្តារលទ្ធភាពពលកម្ម និងបរិយាបន្នសង្គមនៅកម្ពុជា។

### ព័ត៌មានសំខាន់ៗក្នុងខេត្តកំពង់ស្ពឺ

**១៩%** នៃស្ត្រីអាយុ១៥-៤៩ឆ្នាំ ដែលធ្លាប់មានប្តី ឬដៃគូស្និទស្នាលធ្លាប់រងអំពើហិង្សាលើរាងកាយ ផ្លូវភេទឬផ្លូវចិត្តប្រព្រឹត្តដោយប្តី/ដៃគូស្និទ្ធស្នាល។ អត្រាទូទាំងប្រទេសមានចំនួន២១%។[១]

**៦,២%** នៃប្រជាជនសរុបក្នុងខេត្តកំពង់ស្ពឺដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅមានពិការភាពក្នុងទម្រង់ផ្សេងៗ (លំបាកខ្លះៗ លំបាកខ្លាំង និងមិនអាចធ្វើអ្វីកើត)។ អត្រាពិការភាពទូទាំងប្រទេសមានអត្រា ២៤,៤%។[២]

**PRC OPDs** មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PRC) និងអង្គការតំណាងជនមានពិការភាព (OPDs) ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការគាំទ្រចាំបាច់នានាដល់ជនមានពិការភាពនៅក្នុងខេត្តនេះ។

### ដៃគូរបស់កម្មវិធី ACCESS 2

កម្មវិធី ACCESS 2 នឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសង្គមស៊ីវិល រួមទាំងអង្គការមិនមែនរដ្ឋាភិបាល បណ្តាញអង្គការតំណាងជនមានពិការភាព ក្រុមគាំទ្រស្ត្រី និងអង្គការតំណាងជនជាតិដើមភាគតិច ដើម្បីចូលរួមអនុវត្តន៍ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព(NDSP) របស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយប្រសិទ្ធភាព។

[១] ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២០២២

[២] ជនមានពិការភាពនៅកម្ពុជា៖ ការរកឃើញពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤ និង២០២១-២០២២

### ផ្នែកបរិយាបន្នពិការភាព

- ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត (P-DAC)
- មន្ទីរសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា (មន្ទីរស.អ.យ.)
- មន្ទីរសុខាភិបាល
- អង្គការតំណាងជនមានពិការភាព (OPDs) ឬអង្គការវេទិកាស្ត្រីមានពិការភាព (WWDFs)
- អង្គការជនពិការកម្ពុជា (CDPO)
- អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន (PAfID)
- អង្គការ UNICEF

### ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)

- មន្ទីរកិច្ចការនារី
- មន្ទីរសុខាភិបាល
- តុលាការខេត្ត/ក្រុង
- ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ខេត្ត និងស្រុក
- មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និង ការិយាល័យភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women)
- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)

### ផ្នែកស្តារលទ្ធភាពពលកម្ម

- មន្ទីរសង្គមកិច្ចអតីយុទ្ធជន និងយុវនីតិសម្បទា (មន្ទីរស.អ.យ.)
- សាខាមូលនិធិជនពិការ និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា
- មន្ទីរសុខាភិបាល និងមូលដ្ឋានសុខាភិបាល
- គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហមកម្ពុជា (ICRC)
- អង្គការ OIC កម្ពុជា
- អង្គការតំណាងជនមានពិការភាព (OPDs)

# សកម្មភាពចម្បងៗ

## អំពើហិង្សាទាក់ទងនឹងយេនឌ័រ

- ធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាសម្រាប់ជនរងគ្រោះដោយអំពើហិង្សា ទាំងមាន និងមិនមានពិការភាព តាមរយៈការអភិវឌ្ឍន៍សមត្ថភាពដល់អ្នកឆ្លើយតបសេវាជួរមុខ។
- ពង្រឹងយន្តការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ។
- អនុវត្តសាកល្បងក្របខ័ណ្ឌ RESPECT WOMEN (អនុវត្តសាកល្បងយុទ្ធសាស្ត្រទាំង៧ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី)។
- បង្កើត និងដាក់ឱ្យដំណើរការកន្លែងផ្តល់សេវាចម្រុះ។
- ពង្រឹងសេវាបញ្ជូនផ្នែក GBV ឱ្យកាន់តែរឹងមាំ។
- ផ្សព្វផ្សាយការយល់ដឹងពីច្បាប់ពាក់ព័ន្ធនឹង GBV និងសិទ្ធិជនមានពិការភាពនៅសហគមន៍។
- ផ្តល់សេវាផ្នែកច្បាប់ ប្រឹក្សាផ្លូវចិត្ត ព្យាបាលផ្លូវចិត្ត ផ្នែកសង្គម សុខភាព និងជម្រកសុវត្ថិភាព។
- ពង្រឹងការគ្រប់គ្រងករណីGBV និងការប្រើប្រាស់ប្រព័ន្ធឌីជីថលដើម្បីប្រមូល និងគ្រប់គ្រងទិន្នន័យ GBV។

## បរិយាបន្នពិការភាព

- គាំទ្រដល់ដំណើរការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត (P-DAC) រួមទាំងការរៀបចំផែនការការងារ ថវិការបាយការណ៍ និងការតាមដានការអនុវត្ត NDSP។
- បង្កើនសមត្ថភាពរបស់មន្ទីរ ស.អ.យ. ក្នុងការពង្រឹងការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មជនមានពិការភាព និងការប្រើប្រាស់ទិន្នន័យពិការភាពពីប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាព (DMIS)។
- ធ្វើការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការតំណាងជនមានពិការភាព (OPDs) ឬអង្គការវេទិកាស្ត្រីមានពិការភាព (WWDFs) ដើម្បីគាំទ្រដល់លទ្ធភាពរបស់ជនមានពិការភាពក្នុងការទទួលបានសេវាសង្គមផ្សេងៗ និងកម្មវិធីជំនួយសង្គម។
- ធ្វើការជាមួយអង្គការតំណាងជនមានពិការភាព (OPDs) ឬអង្គការវេទិកាស្ត្រីមានពិការភាព (WWDFs) ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមនៅមូលដ្ឋានលើបរិយាបន្នពិការភាពនៅក្នុងកម្មវិធីវិនិយោគឃុំ/សង្កាត់ (CIPs)។
- ពង្រឹងសមត្ថភាពដល់អង្គការតំណាងជនមានពិការភាព (OPDs) ឬអង្គការវេទិកាស្ត្រីមានពិការភាព (WWDFs) និងដៃគូនៅមូលដ្ឋានដើម្បីឆ្លើយតបឱ្យកាន់តែប្រសើរទៅនឹងតម្រូវការ និងការស្វែងរកការគាំទ្រដល់ការពង្រឹងសិទ្ធិជនមានពិការភាព។
- បង្កើនការយល់ដឹងអំពីបរិយាបន្នពិការភាព។

## ការស្តារលទ្ធភាពពលកម្ម

- គាំទ្រដល់ដំណើរការនៃការផ្ទេរសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាឱ្យស្ថិតនៅក្រោមវិស័យសុខាភិបាល។
- គាំទ្រការកសាងសមត្ថភាពដល់អ្នកផ្តល់សេវាជួរមុខលើការផ្តល់សេវាស្តារលទ្ធភាពពលកម្ម។
- ពង្រឹងយន្តការសម្របសម្រួល និងយន្តការបញ្ជូនបន្តរវាងមូលដ្ឋានសុខាភិបាល និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា។

សូមចូលទៅកាន់គេហទំព័រ
អាសយដ្ឋាន៖ អគារអាទីណា ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទការិយាល័យ៖ (៨៥៥) ១២ ៨៧៦ ៥៤៩
សារអេឡិចត្រូនិក៖ info@access2cambodia.org
គេហទំព័រ៖ www.access2cambodia.org